ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ សសរ

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះស្រាវជ្រាវត្រួតពិនិត្យ និងបូកសរុបការខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :**

- បង្កើតគណៈកម្មការចំរុះស្រាវជ្រាវត្រួតពិនិត្យ និងបូកសរុបការខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ ក្នុងឧបទ្ទវហេតុ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ នៅក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ព្រុំ | សុខា | ប្រធាន |
| ២- | ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | អនុប្រធាន |
| ៣- | ឯកឧត្តម | ចាយ | សាំងយុន | សមាជិក |
| ៤- | ឯកឧត្តម | ហ៊ុល | លឹម | សមាជិក |
| ៥- | ឯកឧត្តម | ប៊ុន | អ៊ុយ | សមាជិក |
| ៦- | ឯកឧត្តម | គីម | ស៊ីថន | សមាជិក |
| ៧- | លោក | ម៉ប់ | សារិន | សមាជិក |
| ៨- | ឯកឧត្តម | វង្ស | ពិសេន | សមាជិក |
| ៩- | ឯកឧត្តម | នេត | សាវឿន | សមាជិក |
| ១០- | ឯកឧត្តម | សុខ | ចិន្តា | សមាជិក |

**ប្រការ ២ :**

- គណៈកម្មការចំរុះមានភារកិច្ចស្រាវជ្រាវស្រួចពិនិត្យ វាយតំលៃ ដើម្បីកត់ត្រាបូកសរុបការបាត់បង់ ការខូចខាតជាក់ស្តែងទ្រព្យសម្បត្តិ សិការៈ មធ្យោបាយដឹកជញ្ជូន និងសំណង់ផ្សេងៗរួចរាយការណ៍ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :**

- គណៈកម្មការចំរុះមានសិទ្ធិបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ នៅទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់សំរបសំរួលការងារជាប្រចាំ និងអនុគណៈកម្មការចំរុះមួយ ដើម្បីអនុវត្តភារកិច្ចផ្ទាល់ តាមការកំណត់ ដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសំរេចនេះ ។

**ប្រការ ៤ :**

- គណៈកម្មការចំរុះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីលើលិខិតផ្លូវការ ។

**ប្រការ ៥ :**

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៣

**ហ៊ុន សែន**

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ